# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា២នៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**មាត្រាមួយ .-**

មាត្រា២នៃអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវបានធ្វើការកែសម្រួលដូចតទៅ ៖

**មាត្រា ២ .-ថ្មី**

សមាសភាពគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស មានដូចតទៅ ៖

១- អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធាន

| | | |
|---|---|---|
| ២- រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | មួយរូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | មួយរូប | សមាជិក |
| ៤- រដ្ឋលេខាធិការក្រសួងការពារជាតិ | មួយរូប | សមាជិក |
| ៥- អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | មួយរូប | សមាជិក |
| ៦- ប្រធាននាយកដ្ឋានឥស្សរិយយសទីស្ដីការគណៈរដ្ឋមន្ត្រី | | លេខាធិការ។ |

សមាសភាពជាក់ស្ដែងនៃគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយសត្រូវតែងតាំងដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រាពីរ ៈ-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ៈ-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មការពិនិត្យលក្ខណសម្បត្តិ វរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

* * * * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណូមពរចាំបាច់ក្នុងការលើកទឹកចិត្ត និង ដើម្បីអោយការជូនគ្រឿងឥស្សរិយយសរបស់ជាតិមានភាពសុក្រឹតល្អ

## សំរេច

**មាត្រា ១.** -

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ។

**មាត្រា ២. -**

សមាសភាពគណៈកម្មការនេះ រួមមាន :

| | |
|---|---|
| ១- ឯកឧត្តម អគ្គលេខាធិការរាជរដ្ឋាភិបាល | ប្រធាន |
| ២- ឯកឧត្តម រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | អនុប្រធាន |
| ៣- ឯកឧត្តម រដ្ឋលេខាធិការក្រសួងមហាផ្ទៃ មួយរូប | សមាជិក |
| ៤- ឯកឧត្តម រដ្ឋលេខាធិការក្រសួងការពារជាតិ មួយរូប | សមាជិក |
| ៥- លោកប្រធាននាយកដ្ឋានឥស្សរិយយស នៃទីស្តីការគណៈរដ្ឋមន្ត្រី | លេខាធិការ |

**មាត្រា ៣. -**

គណៈកម្មការនេះ មានភារកិច្ច :

- រៀបចំលក្ខណ្ឌ សំរាប់ការទទួលគ្រឿងឥស្សរិយយសចំពោះមន្ត្រីរាជការ
- ពិនិត្យលក្ខណសម្បត្តិវរជនដែលមានស្នាដៃ និងគុណបំណាច់ដ៏ខ្ពង់ខ្ពស់ក្នុងបុព្វហេតុការពារបូរណភាពទឹកដី ឯករាជ្យ សន្តិភាព ប្រជាធិបតេយ្យ និង ក្នុងការងារស្តារនឹងអភិវឌ្ឍន៍ប្រទេសជាតិ
- ពិនិត្យចំនួនលក្ខណសម្បត្តិ មន្ត្រីរាជការ ទាំងឡាយដែលក្រសួង ស្ថាប័នរដ្ឋនានា ស្នើមកសុំគ្រឿងឥស្សរិយយស
- ពិនិត្យ សំរេច និង ធ្វើសំណើដាក់ជូនសម្តេចនាយករដ្ឋមន្ត្រី លើប្រភេទគ្រឿងឥស្សរិយយសតាមទំហំស្នាដៃ ដែលបានបំពេញការងារដើម្បីជាប្រយោជន៍ជាតិ
- ធ្វើសំណើសុំគ្រឿងឥស្សរិយយសជូន មន្ត្រី រាជការ រៀងរាល់ ២ ឆ្នាំម្តង ។

**មាត្រា ៤. -**

គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតអោយមានគណៈកម្មការមួយ ដើម្បីពិនិត្យលក្ខណសម្បត្តិបេក្ខជនដែលត្រូវស្នើសុំគ្រឿងឥស្សរិយយស ដែលមានថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ផ្ទាល់ជាប្រធានគណៈកម្មការ និង ថ្នាក់ដឹកនាំអង្គភាពសំខាន់ៗ ក្រោមឱវាទក្រសួង ស្ថាប័ន ជាសមាជិក ហើយបញ្ជូនបញ្ជីបេក្ខជនដែលស្នើសុំគ្រឿងឥស្សរិយយសទាំងនោះមកគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន មន្ត្រីរាជការ ដែលត្រូវផ្តល់ជូនគ្រឿងឥស្សរិយយស ។

**មាត្រា ៥. -**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦. -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង សមាសភាពគណៈកម្មការ ដូចមានចែងក្នុងមាត្រា២ ត្រូវអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ក ៣ ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុង មាត្រា ៤
- គ្រប់ក្រសួង- រដ្ឋលេខាធិការដ្ឋាន
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ